ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ១៥ សប្ដាហ៍ទី៤ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

តម្លៃ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦១ ស្តីពីការតែងតាំងឯកឧត្តម មិន ចណ្ឌីណារុធ ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១២៤៤

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦២ ស្តីពីការតែងតាំងលោកជំទាវ ហង់ លីណា ជាទីប្រឹក្សាអមក្រសួងផែនការមានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១២៤៥

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ, នស/រកត/០២០៩/១៦៣ ស្តីពីការកែសំរួលមាត្រា ២ និងមាត្រា ៥ របស់ព្រះរាជក្រឹត្យ លេខ នស/រកត/០១០០/០០៨ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០០ ស្តីពីការបង្កើត គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ១២៤៦

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦៤ ស្តីពីការតែងតាំងទីប្រឹក្សាផ្ទាល់ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ចំនួន ០២ រូប ១២៤៨

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ,ឯកឧត្តម និងលោកស្រី ចំនួន ១៥ រូប ១២៤៩

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦៦ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ លោកជំទាវ ជុំ សាមីន ១២៥០

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦៧ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ លោក ឆៅ ស៊ីថា ១២៥១

១៣-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦៨ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះនាយទាហាន ចំនួន ០៥ រូប ១២៥២

១៦-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៦៩ ស្តីពីការតែងតាំងលោក ហេង ដាច ជា ឧកញ៉ា ១២៥៣

១៦-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧០ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី ម៉ឹម សំ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ១២៥៤

១៧-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧១ ស្តីពីការតែងតាំងឯកឧត្តម ហ៊ុយ ណាវ៉ា ជាទីប្រឹក្សាឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ១២៥៥

១៧-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧២ ស្តីពីការតែងតាំងឯកឧត្តមវេជ្ជបណ្ឌិត ជា សំអាន ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១២៥៦

១៧-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧៣ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ១២៥៧

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២៤-០២-២០០៩ -អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា ១២៦៣

២៥-០២-២០០៩ -អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូជុប (រួមទាំងទីរ៉ង) ១២៦៧

១៦-០២-២០០៩ -អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៦៩

១៦-០២-២០០៩ -អនុក្រឹត្យលេខ ២៣៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១២៧១

១៦-០២-២០០៩ -អនុក្រឹត្យលេខ ២៣៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៧២

១៦-០២-២០០៩ -អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១២៧៣

១៦-០២-២០០៩ -អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១២៧៤

១៦-០២-២០០៩ -អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៧៥

១៦-០២-២០០៩ -អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៧៧

១៧-០២-២០០៩ -អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១២៧៩

១៧-០២-២០០៩ -អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១២៨១

១៧-០២-២០០៩ -អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្តីពីការតម្លើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការ ១២៨២

១៧-០២-២០០៩ -អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១២៨៣

១៧-០២-២០០៩ -អនុក្រឹត្យលេខ ២៤៦ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១២៨៤

១៧-០២-២០០៩ -អនុក្រឹត្យលេខ ២៤៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៨៥

១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៤៨ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១២៩៦

១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៩៨

១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១២៩៩

១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥១ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១៣០០
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣០១
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៣០៣
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៣០៤
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៣០៩
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៣១១
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣១៣
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥៨ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១៣១៤
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៥៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៣១៦
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៦០ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ និងការងារ ១៣១៧
១៨-០២-២០០៩ -អនុក្រឹត្យលេខ ២៦១ អនក្រ.តត ស្តីពីការតែងតាំងមុខងារនាយទាហាន ១៣២០

២-សេចក្តីសំរេច

២៥-០២-២០០៩ -សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការតែងតាំងទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ១៣២២
២៥-០២-២០០៩ -សេចក្តីសំរេចលេខ ១៥ សសរ ស្តីពីការតែងតាំងទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ១៣២៤

៣-សេចក្តីណែនាំ

២៥-០២-២០០៩ -សេចក្តីណែនាំលេខ ០១ សនណ ស្តីពីការពិនិត្យតាមដានការអនុវត្តវិធានការបិទ អាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) និងល្បែងភ្នាល់កីឡាគ្រប់ប្រភេទ ១៣២៦

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៥-០២-២០០៩ -សេចក្តីជូនដំណឹងលេខ ០០១ សហវ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០០៩ ១៣២៧

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៤-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤១៥៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលេក្ខណៈច្បាប់របស់ក្រុមហ៊ុន អេស៊ា អុី & ស៊ី ១៣២៨

០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៥៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេច ខេ ភី ស៊ី អនឡាញ ខូអិលធីឌី	១៣៣០
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៦៦ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ដាគ ឌី & ស៊ី	១៣៣២
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៦៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អិច ភី (ខេមបូឌា)	១៣៣៤
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៦៩ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្វៀល ហ្គោលដេន ទ្រី អ៊ិនវេសមេន	១៣៣៦
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៧០ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន តូហ្វៀល គ្រុប លីមីធីត	១៣៣៨
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៧១ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន វេស្ដ៏រ៉ាណា អ៊ិនធើណេសិនណល ខនសាល់ធេន លីមីធីត	១៣៤០
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៧២ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ចាន ស៊ីន អេហ្វ្រី ខនស្ត្រាក់សិន	១៣៤២
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៧៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេ ដាយ៉ំមលឃ្យូ អេស (ខេមបូឌា)	១៣៤៤
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៧៤ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន តូហ្គីដ (ខេមបូឌា)	១៣៤៦
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៧៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ិនឈូវេសិន អេនជីនារីង សឺវីស	១៣៤៨
០៤-៨-២០០៨	-លិខិតបញ្ជាក់លេខ ៤១៧៨ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អូសខេន តេត្រូល្យ៉មខបភើរេសិន	១៣៥០

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម មិន ចរណ្ឌីណសាគុជ ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣.រ.ល. ០៩០២. ១៦៤

លេខ : ១៧៣ -ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

[illegible] ស៊ីនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងលោកជំទាវ **ហង់ លីណា** ជាទីប្រឹក្សាក្រសួងផែនការ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៤.០៩០២.១៦៥

លេខ : ១៦២ ច.ល
ច្បាប់ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០០៩
[illegible] រដ្ឋាភិបាល

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០១០០/០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានកែសម្រួលមាត្រា ២ របស់ព្រះរាជក្រឹត្យលេខ នស / រកត / ០១០០ / ០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដូចតទៅ៖

មាត្រា ២ ថ្មី: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រួមមានសមាសភាព៖

១- ឯកឧត្តម ឱម យ៉ិនទៀង	ជាប្រធាន	មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
២- ឯកឧត្តម ចាន់ មិន	ជាអនុប្រធាន	មានឋានៈស្មើ រដ្ឋមន្ត្រី
៣- ឯកឧត្តម អ៊ុត វ៉ាឌី	ជាអនុប្រធាន	មានឋានៈស្មើ រដ្ឋលេខាធិការ
៤- ឯកឧត្តម មិត់ សម្បត្តិ	ជាអនុប្រធាន	មានឋានៈស្មើ រដ្ឋលេខាធិការ
៥- ឯកឧត្តម អ៊ុច ភាន	ជាអនុប្រធាន	មានឋានៈស្មើ រដ្ឋលេខាធិការ
៦- លោកជំទាវ ពុំ ចាន់ធីនី	ជាសមាជិកា	មានឋានៈស្មើ រដ្ឋលេខាធិការ
៧- ឯកឧត្តម មាឌូរ ឡាពីម៉ានី	ជាសមាជិក	មានឋានៈស្មើ រដ្ឋលេខាធិការ
៨- ឯកឧត្តម តិច ចន្ទ័តារា	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៩- ឯកឧត្តម នូ ស្ថាបត្យា	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១០- ឯកឧត្តម ប៉ែន ស៊ិន	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១១- ឯកឧត្តម ភក្តា អ៊ិន	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១២- ឯកឧត្តម ប៊ុ គុយសេង	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៣- ឯកឧត្តម ឈួន ចាន់ថន	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៤- ឯកឧត្តម ជេត ជាលី	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៥- ឯកឧត្តម អ៊ិច សេង	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៦- ឯកឧត្តម ម៉ែន សុផល	ជាសមាជិក	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៧- លោកជំទាវ សុខ សុម៉ាលី	ជាសមាជិកា	មានឋានៈស្មើ អគ្គនាយក
១៨- ឯកឧត្តម ពេញ ធារមុំ	ជាសមាជិក	មានឋានៈស្មើ អគ្គនាយក
១៩- ឯកឧត្តម សៅ លី	ជាសមាជិក	មានឋានៈស្មើ អគ្គនាយក

មាត្រា ២: ត្រូវបានកែសំរួលមាត្រា ៥ របស់ព្រះរាជក្រឹត្យ លេខ នស / រកត / ០១០០ / ០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដូចតទៅ៖

មាត្រា ៥ ថ្មី: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាមាន ២ អគ្គនាយកដ្ឋាន៖

១- អគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្សៈ ទទួលការងារបច្ចេកទេសពាក់ពន្ធ័លើការស្រាវជ្រាវ ប្រមូលពត៌មាន ឯកសារ ធ្វើរបាយការណ៍ពីបទរំលោភសិទ្ធិមនុស្ស ការងារច្បាប់ និងជំនួយការច្បាប់ កោសល្យវិច្ច័យជំនាញនានា និងទទួលតាមផ្នែកនិមួយៗនៃអនុសញ្ញាអន្តរជាតិ បណ្តុះបណ្តាលអប់រំផ្សព្វ-ផ្សាយសិទ្ធិមនុស្ស រៀបចំវេទិកា សាធារណៈមតិ និងបើកលទ្ធភាពឱ្យមានការសួរដេញដោលដោយសេរី ។

២- អគ្គនាយកដ្ឋានរដ្ឋបាល និងពាក្យបណ្តឹងៈ ទទួលការងាររដ្ឋបាល ហិរញ្ញវត្ថុ គ្រប់គ្រង និងសេវានានា បំរើឱ្យគណៈកម្មាធិការ ទំនាក់ទំនងសាធារណៈ ពាក្យបណ្តឹងតវ៉ា រៀបចំបណ្តាញ និងបណ្តុះបណ្តាលមន្ត្រី ឃ្លាំមើលសិទ្ធិមនុស្សពិសេសលើកទឹកចិត្តដោះស្រាយទំនាស់តាមរបៀបសម្រុះសម្រួល ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចស្នើតែងតាំងទីប្រឹក្សា និងអ្នកជំនាញការខ្មែរ និងបរទេស អមគណៈកម្មាធិការដើម្បីជួយសិក្សា និងផ្តល់យោបល់ពីការងារជំនាញនិមួយៗ ។ ទីប្រឹក្សាអ្នកជំនាញការខ្មែរអាចមានឋានៈពីប្រធាននាយកដ្ឋានឡើងទៅ ។

មាត្រា ៣: រាល់បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៥: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បន្ទាប់

ប្រមុខរដ្ឋស្តីទី

មាត្តលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣/៧.០៩០២.១៦៦

លេខ : ១៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិន្តេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៥/១៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម ឃឹម ប៊ុនសុខ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម ខូវ ចីរៈវត្ត មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៥

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣រល.០៥០២.១៦៧

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ ១៦៦ ច.ល
ជើងប្រមូលចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជំនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម គឹម ខួន
២- ឯកឧត្តម ឡុង សារ៉ែន
៣- ឯកឧត្តម ឈឹម សុភន

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១- ព្រះវិសុទ្ធិញ្ញាណ មុំ សយ
២- ឯកឧត្តម មោក សុធារិន
៣- ឯកឧត្តម អោម ចន
៤- វរសេនីយ៍ឯក កែ សុខុម
៥- វរសេនីយ៍ឯក ហែម ម៉ារិទ្ធ
៦- វរសេនីយ៍ឯក ចំនួ ឡៅ
៧- វរសេនីយ៍ទោ ជួង សុខា
៨- វរសេនីយ៍ត្រី រឹម ឈឹមសេង
៩- លោក សុខ ឈុនតេត
១០- លោក ម៉ិន ពៅ
១១- លោក មោក សុគន្ធ
១២- លោក អ៊ុយ ធន

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រក.០៩០២.១៦៩

លេខ : ១៥៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ចំពោះ

លោកជំទាវ ជុំ សាមីន

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបទ្ទាប់

ប្រមុខរដ្ឋស្តីទី៖
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រល.០៩០២.១៦៩

លេខ : ១៥៩ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

ចំពោះ

លោក ពៅ ស៊ីថា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
មគ្គលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧ល.០៩០២.១៧០

លេខ: ១៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១- វរសេនីយ៍ទោ ឃុន ទណ្ណា

២- វរសេនីយ៍ទោ ទ៉ាន់ ដារ៉ាសិទ្ធិ

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១- វរសេនីយ៍ទោ ពៅ សំអាត

២- វរសេនីយ៍ទោ សំ យាន

៣- វរសេនីយ៍ទោ អ៊ុន សារុន

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រណ.០៩០៤.១៧១

លេខ : ១៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ហេង ជាង

ជា

ឧកញ៉ា

ធ្វើនៅព្រះរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩
ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៣៣.០៩០២.១៧២

លេខ : ១៧១ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី ម៉ម សំ អត្តលេខ ០០២៥១២ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣ ណ. ០៩០២. ១៧៣

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ : ១៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជក្រឹត្យ ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងឯកឧត្តម ហ៊ុយ ណារ៉ា ជាទីប្រឹក្សាឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩

ឡាយព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣៧៧.០៩០២.១៧៤

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ ១៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធប្រឆាំងការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងឯកឧត្តម វេជ្ជបណ្ឌិត ជា សំអាន ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣រល.០១០២.១៧៥

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ : ១៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ការ[illegible] ជីនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧៣

ស្តីពី

ការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩

ត្រាស់បង្គាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១..

ត្រូវបានបង្កើត ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលហៅកាត់ថា ក.ស.វ. ដែលជាអង្គការនៅអមទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យតាមដានការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សិក្សាស្រាវជ្រាវបញ្ហាប្រឈម និងពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយលើកយោបល់ជូនរាជរដ្ឋាភិបាល ។

ជំពូកទី ២

មុខងារ និងភារកិច្ច

មាត្រា ២.-

គ.ស.ច. មានមុខងារ និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យតាមដានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលវិវត្តប្រចាំខែ និងប្រចាំឆ្នាំ ដោយប្រមូលទិន្នន័យនិងព័ត៌មានពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ហើយធ្វើការវិភាគនិងរកមូលហេតុ រួចធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវលើប្រធានបទដែលជាបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជះឥទ្ធិពលលើការអភិវឌ្ឍប្រទេស និងលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ
- ចុះធ្វើអង្កេតស្តីពីប្រធានបទពិសេសដែលរាជរដ្ឋាភិបាលឬទីស្តីការគណៈរដ្ឋមន្ត្រីប្រគល់ជូន
- លើកយោបល់ជូនរាជរដ្ឋាភិបាលលើវាលវិធានការដោះស្រាយចាំបាច់នានា សម្រាប់ឆ្លើយតបទៅនឹងស្ថានភាពវិវត្តនិងបញ្ហាប្រឈមក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ធ្វើការព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលអាចកើតមានឡើងនាពេលអនាគត រួចផ្តល់យោបល់ជូនរាជរដ្ឋាភិបាល
- ពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព របាយការណ៍ កិច្ចព្រមព្រៀង និងឯកសារផ្សេងៗទៀត ដែលបណ្តាក្រសួងស្ថាប័នដាក់ស្នើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល
- ចងក្រងទិន្នន័យនិងព័ត៌មានវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រួមទាំងឯកសារលិខិតបទដ្ឋានគតិយុត្តនានា តាមរយៈប្រព័ន្ធគ្រប់គ្រងពត៌មាន
- សហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីផ្លាស់ប្តូរបទពិសោធ ទិន្នន័យ និងព័ត៌មាន
- រៀបចំសិក្ខាសាលានិងផ្តល់បទបង្ហាញលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាលឬទីស្តីការគណៈរដ្ឋមន្ត្រី ។

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
MINISTRE DU PALAIS ROYAL

ជំពូកទី ៣

សមាសភាព

មាត្រា ៣.-

គ.ស.ទ. មានសមាសភាពដូចតទៅ ÷

១. ឥស្សរជនជាន់ខ្ពស់មួយរូប	ជាប្រធាន
២. ឥស្សរជនមួយចំនួន	ជាអនុប្រធាន
៣. ឥស្សរជន ឬអ្នកជំនាញមួយចំនួន	ជាសមាជិក
៤. អ្នកបច្ចេកទេសមួយចំនួនតាមតម្រូវការចាំបាច់	ជាសមាជិកបម្រុង

ប្រធាន អនុប្រធាន សមាជិក និងសមាជិកបម្រុងនៃ គ.ស.ទ. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

មាត្រា ៤.-

គ.ស.ទ. ដឹកនាំដោយប្រធានមានឋានៈស្មើទេសរដ្ឋមន្ត្រីឬរដ្ឋមន្ត្រី ។

ប្រធាន គ.ស.ទ. ជាឥស្សរជនជាន់ខ្ពស់ដែលមានចំណេះវិជ្ជាកម្រិតឧត្តមសិក្សាឡើងទៅ មានសមត្ថភាព និងមានបទពិសោធខ្ពស់ក្នុងនិង/ឬក្រៅប្រទេស លើមុខជំនាញណាមួយ ជាអាទិ៍ខាងសេដ្ឋកិច្ច នយោបាយ រដ្ឋបាលសាធារណៈ ។

ប្រធាន គ.ស.ទ. មានអនុប្រធានមួយចំនួនសម្រាប់ជួយការងារ ដែលមានឋានៈស្មើរដ្ឋមន្ត្រី ។
អនុប្រធាន គ.ស.ទ. ជាឥស្សរជនដែលត្រូវមានគុណវុឌ្ឍិដូចប្រធាន គ.ស.ទ. ដែរ ។

មាត្រា ៥.-

សមាជិក គ.ស.ទ. ជាអ្នកជំនាញដែលត្រូវមានគុណវុឌ្ឍិដូចខាងក្រោម ÷

- មានចំណេះវិជ្ជាកម្រិតឧត្តមសិក្សាឡើងទៅ
- មានចំណេះដឹងទូទៅកម្រិតខ្ពស់
- មានបទពិសោធការងារក្នុងនិង/ឬក្រៅប្រទេស លើមុខជំនាញណាមួយច្បាស់លាស់ ជាអាទិ៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សេវាកម្ម
- មានការយល់ដឹងផ្នែកនយោបាយ ជាពិសេសនយោបាយរបស់រាជរដ្ឋាភិបាល ។

សមាជិក គ.ស.ទ. អាចមានឋានៈស្មើរដ្ឋមន្ត្រី រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការ ។

ROYAUME DU CAMBODGE • LE MINISTRE ... ROYAL

សមាជិកបម្រុង គ.ស.ទ. ជាអ្នកបច្ចេកទេសកម្រិតខ្ពស់ពីគ្រប់វិស័យ មានសញ្ញាបត្របណ្ឌិតនិងមានបទពិសោធវិជ្ជាជីវៈយ៉ាងតិច៣ឆ្នាំ ក្រោយទទួលបានសញ្ញាបត្របណ្ឌិត មានឋានៈស្មើអគ្គនាយក ។

មាត្រា ៦.-

សមាជិក គ.ស.ទ. ចែកចេញជា សមាជិកអចិន្ត្រៃយ៍ និងសមាជិកមិនអចិន្ត្រៃយ៍ ។

សមាជិកអចិន្ត្រៃយ៍ជាសមាជិកដែលបម្រើការងារពេញម៉ោងនៅ គ.ស.ទ. ។

សមាជិកមិនអចិន្ត្រៃយ៍ជាសមាជិកដែលបម្រើការងារនៅក្រសួង ស្ថាប័នណាមួយ ហើយបំពេញការងារនៅ គ.ស.ទ. បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ៧.-

គ.ស.ទ. អាចមានអ្នកជំនាញការជាតិនិងអន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញនិងមានបទពិសោធខ្ពស់ សម្រាប់ជួយការងារជាទីប្រឹក្សាបច្ចេកទេស ។

ជំពូកទី ៤
រចនាសម្ព័ន្ធ

មាត្រា ៨.-

គ.ស.ទ. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់កិច្ចដំណើរការការងារប្រចាំថ្ងៃ ។

មាត្រា ៩.-

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.ស.ទ. ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៥
កិច្ចដំណើរការការងារ

មាត្រា ១០.-

គ.ស.ទ. បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន គ.ស.ទ. ឬតាមសេចក្តីបង្គាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រីឬរាជរដ្ឋាភិបាល ។

គ.ស.ទ. មានសិទ្ធិអញ្ជើញតំណាងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ជាថ្នាក់ដឹកនាំនិងថ្នាក់បច្ចេកទេស ឱ្យមកចូលរួមប្រជុំ ដើម្បីជួយបំភ្លឺនិងផ្តល់ព័ត៌មានពិស្តារបន្ថែមតាមការចាំបាច់ ។

មាត្រា ១១.-

គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធមានភារកិច្ចផ្តល់ឯកសារ ទិន្នន័យ និងព័ត៌មាន ហើយផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធជូន **ក.ស.ទ.** ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ ជូនទីស្តីការគណៈរដ្ឋមន្ត្រីនិងរាជរដ្ឋាភិបាល ។

មាត្រា ១២.-

ក.ស.ទ. ត្រូវមានតំណាងចូលរួមប្រជុំក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំនានាដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រីឬដោយក្រសួង ស្ថាប័ននានា ដើម្បីអាចបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា២ខាងលើ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

មាត្រា ១៣.-

ក.ស.ទ. មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន ។

ជំពូកទី ៦
ប្រភពធនធាន

មាត្រា ១៤.-

ក.ស.ទ. មានប្រភពធនធាន ផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ក.ស.ទ. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

ជំពូកទី ៧
អន្តរប្បញ្ញត្តិ

មាត្រា ១៥.-

សមាសភាព រចនាសម្ព័ន្ធ និងមន្ត្រីបម្រើការងារនៅក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវផ្ទេរឱ្យទៅបម្រើការក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រោយពីព្រះរាជក្រឹត្យនេះចូលជាធរមាន ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ១៦..

អនុក្រឹត្យលេខ៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៧..

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វគ្រប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រល.០៩០២.១៧៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ ១៧៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.-

អនុលោមតាមមាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតឡើងនៅក្រសួងការពារជាតិ ដែលមានសមាសភាព :

-រដ្ឋមន្ត្រីក្រសួងការពារជាតិ	ប្រធាន
-អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ	អនុប្រធាន
-រដ្ឋលេខាធិការក្រសួងការពារជាតិគ្រប់រូប	សមាជិក
-អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទគ្រប់រូប	សមាជិក
-នាយក នាយកដ្ឋាននីតិកម្ម ក្រសួងការពារជាតិ	លេខាធិការ

មាត្រា២.-

ក្រុមប្រឹក្សាយោធាមានភារកិច្ចពិនិត្យ សិក្សា ពិចារណា ដើម្បីរៀបចំសំរួលរាល់លិខិតបទដ្ឋានទាំងឡាយដែលទាក់ទងទៅនឹងយោធាមុននឹងផ្ញើជូនទៅគណៈរដ្ឋមន្ត្រីសម្រេច ។

ក្រុមប្រឹក្សាយោធាធ្វើការប្រជុំពេញអង្គ ដើម្បីធ្វើសេចក្តីសម្រេច ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអាចអញ្ជើញបន្ថែមសមាសភាពដែលមានការពាក់ព័ន្ធចូលរួម ។

សមាជិកក្រុមប្រឹក្សាយោធាត្រូវចូលរួមប្រជុំតាមការកំណត់របស់ប្រធាន ។

មាត្រា៣.-

ត្រូវបានបង្កើតក្រុមការងារស្រាវជ្រាវមួយសំរាប់ជួយការងារក្រុមប្រឹក្សាយោធាដែលមានសមាសភាព :

-រដ្ឋលេខាធិការក្រសួងការពារជាតិ ០១រូប	ប្រធាន
-អនុរដ្ឋលេខាធិការក្រសួងការពារជាតិ មួយចំនួន	សមាជិក
-មេបញ្ជាការកងទ័ពជើងគោក	សមាជិក
-មេបញ្ជាការកងទ័ពជើងទឹក	សមាជិក
-មេបញ្ជាការកងទ័ពជើងអាកាស	សមាជិក
-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
-អគ្គលេខាធិការក្រសួងការពារជាតិ	សមាជិក
-អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស	សមាជិក
-អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ	សមាជិក
-អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា	សមាជិក

-សាកលវិទ្យាធិការ សាកលវិទ្យាល័យការពារជាតិ	សមាជិក
-អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស	សមាជិក
-អគ្គនាយក មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម	សមាជិក
-មេបញ្ជាការគ្រប់យោធភូមិភាគ	សមាជិក
-ប្រធានស្ថាប័នអយ្យការយោធា	សមាជិក
-ប្រធានស្ថាប័នតុលាការយោធា	សមាជិក
-នាយក នាយកដ្ឋានអធិការកិច្ច	សមាជិក
-នាយក នាយកដ្ឋានបុគ្គលិក	សមាជិក
-នាយកទីចាត់ការបុគ្គលិក	សមាជិក
-នាយកទីចាត់ការហិរញ្ញវត្ថុ	សមាជិក
-នាយក នាយកដ្ឋាននីតិកម្ម	លេខាធិការ

មាត្រា៤.-

ក្រុមការងារស្រាវជ្រាវមានតួនាទីភារកិច្ចដូចតទៅ ៖

-សិក្សាស្រាវជ្រាវអំពីការតាក់តែង ការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានាដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសំរេចទាំងឡាយដែលទាក់ទងនឹងកងយោធពលខេមរភូមិន្ទ ឱ្យបានត្រឹមត្រូវតាមទំរង់បែបបទ និងស្របតាមឋានានុក្រមលិខិតបទដ្ឋានដែលនៅជាធរមានមុននឹង ដាក់ជូនប្រជុំពេញអង្គក្រុមប្រឹក្សាយោធាឬដាក់ជូនប្រធានក្រុមប្រឹក្សាយោធាពិនិត្យសម្រេច ។

-ទំនាក់ទំនងសហការជាមួយស្ថាប័ន,អង្គភាពក្នុងកងយោធពលខេមរភូមិន្ទ និងស្ថាប័នអង្គភាពស៊ីវិល ផ្សេងៗទៀតដើម្បីពិនិត្យកែសំរួលខ្លឹមសារលិខិតបទដ្ឋានទាំងឡាយឱ្យបានស្របតាមកម្មវិធីនយោ-បាយរបស់រាជរដ្ឋាភិបាលនិងកងយោធពលខេមរភូមិន្ទ ។

-ធ្វើកិច្ចការមួយចំនួនទៀតតាមការប្រគល់ភារកិច្ចបន្ថែមពីក្រុមប្រឹក្សាយោធា ។

-ក្រុមការងារស្រាវជ្រាវបន្ទាប់ពីបានធ្វើការប្រជុំត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលជូនប្រធាន ក្រុមប្រឹក្សាយោធាធ្វើការពិនិត្យសម្រេច ។

-សមាជិកក្រុមការងារស្រាវជ្រាវត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា៥.-

ការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាយោធា និងក្រុមការងារស្រាវជ្រាវដូចមានចែងក្នុងមាត្រា១ និងមាត្រា៣ នៃអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា៦.-

អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធានិងអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការកែសំរួលមាត្រា១ និងមាត្រា៣ វាក្យខណ្ឌទី១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ បាញ់

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២ . អនក្រ . បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូជុប (រួមទាំងនីវ៉េ)

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ការអនុវត្តនីព្រះរាជក្រម ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនជលផល
- បានឃើញកិច្ចសន្យាទិញ និង កិច្ចសន្យាជួល សំរាប់ចំការកៅស៊ូជុប ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប ខូអិលធីឌី
- តាមសំណើរបស់គណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

ស ម្រេ ច

មាត្រា ១ : បញ្ចប់ស្ថានភាពគតិយុត្តិចំការកៅស៊ូជុប ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

មាត្រា ២ : ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូជុប (រួមទាំងទីរង) ទៅឱ្យក្រុមហ៊ុន **សុភក្តិនីកា អ៊ិនវេសមេន គ្រុប ខូអិលធីឌី** (SOPHEAK NIKA INVESTMENT GROUP CO., LTD.) ដើម្បីបន្តគ្រប់គ្រង ស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ និង កិច្ចសន្យាជួលសំរាប់ចំការកៅស៊ូជុប ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន **សុភក្តិនីកា អ៊ិនវេសមេន គ្រុប ខូអិលធីឌី** (SOPHEAK NIKA INVESTMENT GROUP CO., LTD.) ចាប់ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

មាត្រា ៣ : រំសាយក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូជុប បញ្ចប់ដំណែងប្រធានអគ្គនាយកចំការកៅស៊ូជុប និង បញ្ចប់ដំណែងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូជុប ចាប់ពីថ្ងៃ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

មាត្រា ៤ : ផ្ទេរឯកឧត្តម **ម៉ក់ គីមហុង** ប្រធានអគ្គនាយកចំការកៅស៊ូជុប ចូលមកបំរើការងារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

មាត្រា ៥ : ចំការកៅស៊ូជុបត្រូវប្រគល់ត្រា និងឯកសារពាក់ព័ន្ធទាំងអស់រួមទាំងឯកសារក្នុងកុំព្យូទ័រ មកគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសម្ភារៈកសិកម្ម និង ក្រុមហ៊ុនផលផល ដើម្បីរក្សាទុក ។

មាត្រា ៦ : ថវិកាដែលនៅសល់ក្នុងគណនី និង បេឡា របស់ចំការកៅស៊ូជុប ត្រូវផ្ទេរចូលថវិការដ្ឋ ។ បិទរាល់គណនីធនាគារទាំងអស់របស់ចំការកៅស៊ូជុប ចាប់ពីថ្ងៃ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

មាត្រា ៧ : អនុក្រឹត្យលេខ ១៤ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូជុប ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ តទៅ ។

មាត្រា ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៣៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តក្រចេះ ចំនួន ១៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ និង ប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

	លោក	**ចឺ ជា**	អនុប្រធានមន្ទីរ សអយ ខេត្តក្រចេះ

ខ-មេដាយប្រាក់ការងារ :

១	លោក	**ជ មានអាន**	អនុប្រធានមន្ទីរ សអយ ខេត្តក្រចេះ
២	លោក	**ស្រី និត**	ប្រធានការិយាល័យ សុខុមាលភាពសង្គម
៣	លោកស្រី	**ឥម សិទ្ធី**	ប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ

គ-មេដាយសំរិទ្ធការងារ :

១-	លោក	**ចាន់ សុគុណ**	អនុប្រធានមន្ទីរ សអយ ខេត្តក្រចេះ
២-	លោក	**អៀម សារ៉ាត**	ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក
៣-	លោក	**សន សាន**	អនុបធានការិយាល័យរដ្ឋបាល និងបុគ្គលិក
៤-	លោក	**មាស ម៉ាន់ថា**	ប្រធានការិយាល័យ អតីតយុទ្ធជន
៥-	លោកស្រី	**ឈាវ មុំ**	អនុប្រធានការិយាល័យ អតីតយុទ្ធជន

៦- លោក គួ ជុំខ ប្រធានការិយាល័យ សុខុមាលភាពកុមារ
៧- លោក ថាច់ សុដ្ឋា អនុប្រធានការិយាល័យហិរញ្ញវត្ថុ និង ផែនការ
៨- លោកស្រី នុត សុទីម អនុប្រធានការិយាល័យហិរញ្ញវត្ថុ និង ផែនការ
៩- លោកស្រី ឈួន ស៊ីយោន អនុប្រធានការិយាល័យ សអយ ស្រុកសំបូរ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៣៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

